ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្ដីពី
# សកម្មភាពការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សកម្មភាពការងាររួម

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន២.៥៦១.៩៥៧ហិកតា ស្មើនឹង៩៩,៨០% នៃផែនការ២.៥៦៧.១៣០ហិកតា តិចជាងឆ្នាំមុនចំនួន២.៦១៥ហិកតា។ មកទល់ពេលនេះ ប្រជាកសិករបាននឹងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង៣០,៧៧%នៃផ្ទៃដីអនុវត្ត ដែលទទួលបានទិន្នផលគិតជាមធ្យម២,៩៦៣តោនក្នុងមួយហិកតា និងខិតខំជំរុញការងារដាំដុះដំណាំរដូវប្រាំងជាបន្តទៀត។ ទន្ទឹមនឹងនេះ ក្រសួងកំពុងបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវ យកចិត្តទុកដាក់លើការគ្រប់គ្រង និងរក្សាទឹកទុកឲ្យបានគត់មត់សម្រាប់រដូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗ ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឲ្យអស់ពីលទ្ធភាពនៅកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកិច្ចប្រជុំមួយដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង គ្រប់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីវាយតម្លៃ និងបូកសរុបលទ្ធផលបឋមនៃការងារបង្កបង្កើនផលរដូវវស្សាឆ្នាំ២០១៥ និងវិធានការជំរុញការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៥-២០១៦។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្ដាវិស័យ

### ១ វិស័យដំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៣.៥៥៣.៨៨៧ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៤៣៤.៣៩៧ហិកតា និងគ្រឿងយន្តចំនួន៣.១១៩.៤៩០ហិកតា លើសឆ្នាំមុនចំនួន៥៧៣.៧៧០ហិកតា
- ផ្ទៃដីសាបសម្រេចបានចំនួន៧១.០៧៣ហិកតា តិចជាងឆ្នាំមុនចំនួន៤២.២៨៩ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន២.៥៦១.៩៥៧ហិកតា ស្មើនឹង៩៩,៨០% នៃផែនការ២.៥៦៧.១៣០ហិកតា តិចជាងឆ្នាំមុនចំនួន២.៦១៥ហិកតា និងស្រូវតាមប្រភេទមាន៖
  + ស្រូវស្រាលចំនួន៥៨៣.៧០៦ហិកតា (ក្នុងនោះ ស្រូវបង្កើនរដូវចំនួន១៣៣.៧២៦ហិកតា) តិចជាងឆ្នាំមុនចំនួន៧៧.៤០០ហិកតា
  + ស្រូវកណ្ដាលចំនួន១.៣១៤.៧៦៧ហិកតា លើសឆ្នាំមុនចំនួន៥៨.៥០៨ហិកតា
  + ស្រូវធ្ងន់ចំនួន៥៧៩.៩៤២ហិកតា លើសឆ្នាំមុនចំនួន២៩.៣៦២ហិកតា
  + ស្រូវចម្ការចំនួន៣៦.៧៨៣ហិកតា តិចជាងឆ្នាំមុនចំនួន៧.៣០៥ហិកតា
  + ស្រូវឡើងទឹកចំនួន៤៦.៧៥៩ហិកតា តិចជាងឆ្នាំមុនចំនួន៥.៧៨០ហិកតា។



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Bassak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129. Fax : (855) 23 - 217 320

- សន្ទូង-ពង្រោះប៉ះពាល់សរុបចំនួន២៤២.៤១៦ហិកតា ស្មើនឹង៩% នៃផ្ទៃដីអនុវត្តចំនួន២.៥៦១.៩៥៧ហិកតា ក្នុងនោះខូចខាតទាំងស្រុងអស់ចំនួន២៥.៧៦០ហិកតា។

- ផ្ទៃដីប្រមូលផលសរុបនឹងអាចទទួលបានចំនួនប្រមាណ២.៥៣៦.១៩៧ហិកតា តែតិចជាងឆ្នាំ២០១៤ចំនួន ១.៧៧៩ហិកតា។ ទិន្នផលជាមធ្យមប៉ាន់ស្មានអាចនឹងទទួលបាន២,៨២៩តោនក្នុងមួយហិកតា លើសឆ្នាំមុន១៤គីឡូក្រាមក្នុងមួយហិកតា និងបរិមាណផលសរុបប្រមាណ៧.១៧៤.៥៤៥តោន កើនលើសឆ្នាំមុន៣១.០២៨តោន។

### ១.២ លទ្ធផលប៉ាន់ស្មានដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦ គិតរហូតដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ អនុវត្តបានចំនួន ២០៤.២៧៩ហិកតា ស្មើនឹង៤៨,៩៥% នៃផែនការ៤១៧.៣២៥ហិកតា តិចជាងរយៈពេលដូចគ្នានៃឆ្នាំមុនចំនួន១៥.១៣៥ ហិកតា។ ដោយផ្អែកលើនិន្នាការនេះ ក្រសួងបានប៉ាន់ស្មានថាផ្ទៃដីសរុបអាចសម្រេចបានចំនួន៤៦៥.១៦៧ហិកតា ដែលក្នុងនោះអាចប្រមូលផលបានចំនួន៤៦០.០៦២ហិកតា ហើយបរិមាណផលស្រូវសរុបស្ថិតក្នុងរង្វង់២.០៥២.៤៧២តោន គឺតិចជាងឆ្នាំមុន១២៨.៤២៤តោន ក្នុងកម្រិតទិន្នផលជាមធ្យមចំនួន៤,៤៦១តោនក្នុងមួយហិកតា(ទិន្នផលឆ្នាំមុន៤,៤៤៣ តោនក្នុងមួយហិកតា)។

### ១.៣ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន១៣.២០៨ហិកតា ស្មើនឹង៣០,៩៣% នៃផែនការ៤២.៦៩៨ហិកតា តិចជាងឆ្នាំមុនចំនួន៣.២៣៨ហិកតា

- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន៣.០១៧ហិកតា ស្មើនឹង១៤,៨៤%នៃផែនការ២០.៣៣១ហិកតា លើសឆ្នាំមុនចំនួន៨៤១ហិកតា។

### ១.៤ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល១១ខែដើមឆ្នាំ២០១៥នេះ មានបរិមាណចំនួន៤៥៦.៩១៧ តោន ដែលមានការកើនឡើងចំនួន១២០.៩៩២តោន(+៣៦%) លើសបរិមាណនាំចេញក្នុងរយៈពេល១១ខែដើមឆ្នាំ ២០១៤ ដែលមានតែ៣៣៥.៩២៥តោន។ ដោយឡែកបរិមាណអង្ករនាំចេញក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ មានចំនួន ៤៨.៧៤៨តោន ដែលមានការកើនឡើងចំនួន១៧.៦១១តោន(+៥៦,៦%) លើសបរិមាណនាំចេញក្នុងខែវិច្ឆិកា ដើមឆ្នាំ ២០១៤ ដែលមានតែ៣១.១៣៧តោន និងនាំចេញទៅកាន់ទិសដៅចំនួន៥៨ប្រទេស។

## ២ ផ្នែកកៅស៊ូ

### ២.១ ការអភិវឌ្ឍន៍ និងផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៧,៥១ | ៧៥៧,១៦ | ៦១៨,៧៧ | ៣៤៩,០០ |
| សរុប I | | ៥០៧,៥១ | ៧៥៧,១៦ | ៦១៨,៧៧ | ៣៤៩,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨,៣៧ | ១៦.០២៧,៨១ | ១៦.៧៥២,១២ | ១៣.៦៤០,៤០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វូរ៉ាប់ប៊ើឌីវឺឡុបមិន (កេនគី) | ៧៨,៥៣ | ២.៤៩៨,០៦ | ២៨១,៩៥ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ២.២៩៨,៩២ | ១.០៥៤,០១ | ៨០១,៦០ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៦៤៥,៩៧ | ៥.៧១១,៣៥ | ៦.០៤០,២១ | ៥.៤២៦,១៨ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៨.៦៦១,៤០ | ៣.២០៤,៣០ | ២.៣៤៥,២០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វូវីសសស៍ (ស្នួល) | ១.៧៤៤,៧៨ | ៤.៣៦៥,៣០ | ២.០២៤,៦៤ | ១.៦១០,០០ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង,មាសហេក) | ២.០២៩,៧០ | ៤.១៤២,៩៥ | ១.១៧០,៣៧ | ៨៦៧,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ៥.៩២៤,៦០ | ១.៤៦៣,២៩ | ១.២៣២,៨០ |

| | | | | | |
|---|---|---|---|---|---|
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦,០៩ | ៥.៧៣១,៤៧ | ៤.៧០៦,៨៨ | ៣.៧១៩,៤០ |
| សរុប II | | ២៨.៩៩៥,៦៣ | ៥៥.៣៦១,៨៦ | ៣៦.៦៩៧,៧៧ | ២៩.៦៤២,៧៨ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៦១.៦៧៧,០០ | ៤.៤១៤,០០ | ៤.៤១៤,០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ១៤០.៣៤៦,០០ | ៦៩.០៥៥,០០ | ៦៧.៨៥៥,០០ |
| សរុប III | | ៧៩.៨១១,០០ | ៣០២.០២៣,០០ | ៧៣.៤៦៩,០០ | ៧២.២៦៩,០០ |
| សរុប I+II+III | | ១០៩.៣១៤,១៤ | ៣៥៨.១៤២,០២ | ១១០.៧៨៥,៥៤ | ១០២.២៦០,៧៨ |

• គួរកត់សម្គាល់ថា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.១៤៧ដុល្លារក្នុងមួយតោន។

## ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមសន្និសីទកៅស៊ូអន្តរជាតិ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ នៅប្រទេសវៀតណាម

- ទទួលជួបជាមួយអង្គការ UNIDO ដើម្បីពិភាក្សាអំពីការទទួលស្គាល់ជាផ្លូវការតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO 17025:2005 ជាមន្ទីរពិសោធន៍តាមស្តង់ដារអន្តរជាតិ

- ចុះបេសកកម្មតាមបណ្តាខេត្តដែលមានចម្ការកៅស៊ូ ដើម្បីចូលរួមសហការរាល់ការងារដែលពាក់ព័ន្ធនឹងបច្ចេកទេសកៅស៊ូ

- វិភាគលទ្ធផលចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិលើកទី១១៣ ជាមួយ IRA (International Rubber Association) ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់សម្រាប់កិច្ចសន្យាកៅស៊ូ TSR (Technically Specified Rubber)

- វិភាគ DRC តាមមេត្រូឡាក់ និងតាមការដុតរក TSC ដោយធ្វើការវិភាគតាមមន្ទីរពិសោធន៍ចំនួន២ដងសម្រាប់ចម្ការពិសោធន៍នីមួយៗ

- លាបថ្នាំរំញោចអេតេហ្វុនលើចម្ការពិសោធន៍ d3, d4, Frequency និងចម្ការពិសោធន៍ Rainquard

- វិភាគ LD លើចម្ការពិសោធន៍ d3 ក្លូន PB217, d4 ក្លូន IRCA230 ចម្ការពិសោធន៍Frequency ចម្ការបង្កាត់ seedling ចម្ការពិសោធន៍LSCT

- បន្តបណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាកលវិទ្យាល័យស្វាយរៀង។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

៣.១ **ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត ការរៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

• ការងារកែលម្អពូជ៖ ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

• ការងារឡជីវឧស្ម័ន៖ ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មដែលមកទល់ពេលនេះ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១៤៧ឡ និង២៨ ឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន១២៩ឡ។

• ចំណីសត្វ៖ បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

• ការងារដំណាំចំណីសត្វ៖ តាមបណ្ដាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

### ៣.២ ការងារបសុពេទ្យាបាល

• លទ្ធផលត្រួតពិនិត្យនិងបង្រ្កាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

ខេត្ត-រាជធានីចំនួន១២ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន៣.១៣៩លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្រ្កាប ដោយបានកក់និងកម្ទេចចោលផលិតផលសាច់ខូចគុណភាពតាមវិធានបសុពេទ្យចំនួន៩៨,២គីឡូក្រាម ណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង និងបង្រ្កាបបទល្មើសអាជីវកម្មខុសច្បាប់ចំនួន១២ករណី។

• ការងារសុខភាពសាធារណៈ៖ ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្ដារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានជាប្រចាំឱ្យស្របតាមលក្ខណៈបច្ចេកទេស។

• ការងារនីតិកម្មនិងវិវាទ៖សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ បានប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីរួច និងបានប្រជុំឆ្លងគណៈកម្មការទី៦ និងគណៈកម្មការទី៣នៃរដ្ឋសភា។ បន្តរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងរៀបចំផែនការយុទ្ធសាស្ត្រវិស័យសុខភាពសត្វនិងផលិតកម្មសត្វរយៈពេល១០ឆ្នាំ(២០១៥-២០២៤)។

### ៣.៣ ការងារស្រាវជ្រាវ៖

• ការងារស្រាវជ្រាវផលិតកម្ម៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន១៦០ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣៣ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤៥ក្បាល គោកំផែងសែន៤២ក្បាល និងគោកើតថ្មី៣ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប២៩៩ក្បាល ក្នុងនោះជ្រូកបាចំនួន៦ក្បាល ជ្រូកមេ៥៣ក្បាល កូនជ្រូក១១៣ក្បាល មេជ្រូកត្រៀមលក់ចំនួន១៥ក្បាល កូនជ្រូកលក់១០០ក្បាល និងកូនជ្រូកងាប់ចំនួន១១ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

• ការងារស្រាវជ្រាវបសុព្យាបាល៖ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ វិទ្យាស្ថានស្រាវជ្រាវបសុព្យាបាលបានរកឃើញមេរោគផ្តាសាយបក្សី២កន្លែងគឺនៅភូមិដង្កត់ធ្នង់ ឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង និងនៅភូមិច្រនៀង ឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប និងពិនិត្យវត្ថុវិភាគសរុបចំនួន៥៧០ករណី។ ក្រសួងបានម្ចាស់ការនិងចាត់វិធានការទប់ស្កាត់ទាន់ពេលវេលាចំពោះការផ្ទុះជំងឺផ្តាសាយបក្សីនៅក្នុងភូមិសាស្ត្រនៃខេត្តទាំងពីរនេះ។

៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖ ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ វិស័យព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- អនុម័តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន២៨កន្លែងរួមមាន៖ ខេត្តកំពង់ឆ្នាំងចំនួន៥កន្លែងមានផ្ទៃដីសរុប

ទំហំ២.៥១៣ហិកតា ខេត្តបាត់ដំបងចំនួន៦កន្លែងមានផ្ទៃដីសរុបទំហំ១.១១០ហិកតា ខេត្តកំពង់ស្ពឺចំនួន៩កន្លែងមានផ្ទៃដីសរុបទំហំ៣.៨៨៨ហិកតា និងខេត្តពោធិ៍សាត់ចំនួន៨កន្លែងមានផ្ទៃដីសរុបទំហំ២.៤៥២ហិកតា

- ធ្វើការផ្សព្វផ្សាយអំពីទស្សនៈទានស្តីពីរេដបូកដល់សមាជិកសហគមន៍ព្រៃឈើ (ជនជាតិដើមភាគតិច) នៅខេត្តស្ទឹងត្រែងចំនួន៣សហគមន៍ព្រៃឈើ ខេត្តរតនគីរីចំនួន៣សហគមន៍ព្រៃឈើ និងខេត្តមណ្ឌលគិរីចំនួន៣សហគមន៍ព្រៃឈើ។

## ៤.២ ការងារអភិរក្សសត្វព្រៃ

- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិក រុក្ខជាតិ និងសត្វព្រៃសៀមប៉ាង
- រៀបចំអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃព្រះរការ ដែលមានទំហំ ៩២១៣២ហិកតា ក្នុងខេត្តព្រះវិហារ
- មានភ្ញៀវទេសចរណ៍បរទេសចំនួន១២នាក់ មកទស្សនាតំបន់អភិរក្សជីវចម្រុះរ៉ុនសៃ អាងត្រពាំងថ្ម
- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំខែនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤កន្លែង (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួន២០៦ប្រភេទ (ប្រហែល២៤.៧៥៨ក្បាល)
- ចុះប្រមូលសំណាកសត្វប្រចៀវរស់បានចំនួន១៧៩ក្បាល សត្វជ្រូងចំនួន២០ក្បាល ដើម្បីធ្វើការពិនិត្យទៅលើឈាម លាមក ទឹកមាត់ ទឹកនោម និងវាស់ប្រវែងស្លាបដើម្បីវិភាគរកមេរោគ និងការបន្តពូជ
- ផ្តល់ចំណីដល់ត្មាតនៅស្ទឹងត្រែង-ក្រចេះ ព្រៃការពារសៀមប៉ាង និងតំបន់ព្រៃការពារព្រះវិហារ ដោយរាប់ឃើញត្មាតសរុបចំនួនប្រមាណ១៥៩ក្បាល។ ការផ្តល់ចំណីដល់ត្មាត ដើម្បីធានាការរស់រានរបស់សត្វត្មាត និងបន្តធ្វើការអង្កេតតាមដាន
- ការពារសំបុកសត្វត្រយ៉ងយក្សចំនួន១១សម្បុក ត្រដក់តូចចំនួន៨សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ និងព្រៃការពារសៀមប៉ាង។ មូលហេតុដែលត្រូវការពារសំបុកសត្វព្រោះថាប្រភេទសត្វស្លាបទាំងនេះជាប្រភេទជិតផុតពូជ និងមានដោយកម្រតាមច្បាប់ស្តីពីព្រៃឈើ
- កំពុងរៀបចំផែនការគ្រប់គ្រងតំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្មបាន៧០%។

## ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន៥៣ក្បាល សត្វកើតថ្មីចំនួន៤ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន២ក្បាល សត្វស្លាប់ចំនួន១២ក្បាល ព្យាបាលសត្វចំនួន៣០ក្បាល យកសំណាកទៅពិសោធន៍ចំនួន៤ក្បាល ធ្វើឲ្យសន្លប់ចំនួន១៣ក្បាល ទម្លាក់សត្វល្អិតចំនួន២ក្បាល វះកាត់សាកសពសត្វចំនួន៨ក្បាល ដាក់លេខកូដចំនួន១ក្បាល ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន១៦០ម$^2$ ជួសជុលផ្លូវចំនួន៤.៧៦៨ម$^2$ កាប់ឆ្ការអនាម័យព្រៃចំនួន៥៦.២០០ម$^2$ និងអប់រំផ្សព្វផ្សាយសិស្សនិស្សិតចំនួន៦នាក់
- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៥៤.៦១៣ក្បាល និងនាំចេញចំនួន៦៧៦ក្បាល។

## ៤.៤ ការងារដាំដើមឈើ

- ស្ថានីយដាំឈើអូរបឹងរូង ខេត្តកំពង់ធំបានបន្តដាំកូនក្រញូង និងធ្នង់បានចំនួន១០ហិកតា។ ការងារដាំឈើឆ្នាំ២០១៥ នៅតាមបណ្តាស្ថានីយទាំងបី៖ ខ្នារង្វាសខេត្តសៀមរាប ស្ថានីយដាំឈើក្បាលឆាយខេត្តព្រះសីហនុ និងអូរបឹងរូងខេត្តកំពង់ធំ សម្រេចបាន៤០៥ហិកតា
- ចម្ការឈើចាស់(ឆ្នាំទី១ ដល់ឆ្នាំទី៥) ដែលមានទំហំផ្ទៃដីសរុប ២.៨១៨ហិកតា នៅស្ថានីយដាំឈើចំនួន ១៦កន្លែង បានបន្តការថែទាំ ភ្ជួរ សម្អាតស្មៅ និងអនាម័យចម្ការឈើ ជាពិសេសគឺពង្រឹងការយាមល្បាត ដើម្បីទប់ស្កាត់ការរុករានរំលោភកាន់កាប់ដីចម្ការឈើ និងភ្លើងព្រៃ
- ការបណ្តុះកូនឈើសម្រាប់ចែកជូនប្រជាពលរដ្ឋដាំអាស្រ័យផលរួមមាន ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើ និងថ្នាលបណ្តុះកូនឈើសម្តេចតេជោ ដោយបណ្តុះពូជឈើគ្រប់ប្រភេទបានចំនួន១៥.៦៥០ដើម និងចែកជូនកសិករដាំអាស្រ័យផលបានចំនួន៨៤.៨៤២ដើម

- ក្រុមការងារស្រាវជ្រាវកំណត់អត្តសញ្ញាណសត្វល្អិត Linvasa បានធ្វើការតាមដាន និងស្រាវជ្រាវជាបន្តតាមរយៈការចុះបេះ និងប្រមូលសំណាកដើមប្រេងខ្យល់តាមបណ្តាឡូត៍គំរូនៅតាមបណ្តាខេត្តមួយចំនួន ដូចជាៈ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តសៀមរាប។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន១ក្រុមហ៊ុន គឺក្រុមហ៊ុនស៊ីងបាយអូថេក(ខេមបូឌា) ខូអិលធីឌី នៅខេត្តក្រចេះក្នុងអនុតំបន់ ៤ ដែលមានផ្ទៃដីទំហំ ២.៣២២ហិកតា និងអនុតំបន់៥ ដែលមានផ្ទៃដីទំហំ ២.៤៤២ហិកតា

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន៥ អតិថិជនចំនួន២នាក់ ដែលមានឈើហ៊ុបមូលចំនួន៤.៥១០ម៣ កូនឈើចំនួន៥៣.៩២៣ដើម អុសចម្រុះចំនួន១.៦៩០ស្ទែរ និងជ័រទឹកចំនួន ១៦៥តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណឈើកែច្នៃចំនួន ៧៥ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណឈើកែច្នៃចំនួន ១៤៩ម៣

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន៣ ស្មើនឹង១២សន្លឹក ដែលមានបរិមាណឈើចំនួន៩២៣ម៣

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន១ ស្មើនឹង៨សន្លឹក ដែលមានបរិមាណឈើឡាំងជ្រុងចំនួន២៥៥ម៣ ។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៥នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន៨៤៥.២៦៥.២២០រៀល និងចំណូលពីសេវាសាធារណៈចំនួន៦៨៧.៤៩០.៣៥២រៀល និង៥.៨៨៧,៥១ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ នៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន២២៦ករណី ដោយបញ្ជូនទៅតុលាការចំនួន១៨២ករណី និងពិន័យអន្តរការណ៍ចំនួន៤៤ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១៨៤ម៣ ឈើអារចំនួន៦០១ម៣ ឈើក្រាក់គ្រញូងចំនួន៥ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៣៧៨គ.ក្រ អនុផលព្រៃឈើ សម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៣៩៥ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន ១៦គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ចុះពង្រឹងការអនុវត្តក្នុងការតាមដានស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ ដេប៉ូឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើនៅខេត្តត្បូងឃ្មុំ ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន៨៦ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានផ្ញើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន ២៥ករណី។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន១.០០០តោន សរុបរយៈពេល១១ខែបានចំនួន១.១២៥តោន ស្មើ១១,២៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៨៧៥តោន

-នេសាទគ្រួសារក្នុងដែននេសាទ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន២៩.៥០០តោន សរុបរយៈពេល១១ខែបានចំនួន

២៧៧.៨៥០តោន ស្មើ៧៩,៣៩% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១២.៨៥០តោន

- នេសាទគ្រួសារតាមវាលស្រែ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន១៦.៣៣៥តោន សរុបរយៈពេល១១ខែបានចំនួន ១១៨.៦៩០តោន ស្មើ៧៩,១៣% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៣១០តោន។

### ៥.១.២ នេសាទសមុទ្រ

ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន១៣.០០០តោន សរុបរយៈពេល១១ខែចំនួន១០២.៥០០តោន ស្មើ៩៣,១៨% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៤.៥០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន១០.៥០០តោន សរុបរយៈពេល១១ខែបានចំនួន១៣៤.៦០០តោន ស្មើ៩៣,៤៧%នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៤៤.៦០០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន២៥.០០០ក្បាល សរុបរយៈពេល១១ខែបានចំនួន២៣០.៥០០ក្បាល ស្មើ៩២,២០%នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៤.៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួនប្រមាណ២០.០០០.០០០កូន សរុបរយៈពេល១១ខែ បានចំនួនប្រមាណ១៨០.០០០.០០០កូន ស្មើ១០០% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួនប្រមាណ៥.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន២.០០០តោន សរុបរយៈពេល១១ខែបានចំនួន៤៨.៥០០តោន ស្មើ៥៩,១៥% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៦.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន៦០០តោន សរុបរយៈពេល១១ខែបានចំនួន ៨.៩០០តោន ស្មើ១១១,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន ១.៤០០តោន

- ការផលិតទឹកត្រីក្នុងខែវិច្ឆិកា អនុវត្តបានចំនួន១.០០០.០០០លីត្រ សរុបរយៈពេល១១ខែបានចំនួន៥៣.០០០.០០០លីត្រ ស្មើ១០៦% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៧.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន៧០០តោន សរុបរយៈពេល១១ខែបានចំនួន៨.៥០០តោន ស្មើ៥៦,៦៧% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២.៥០០តោន

- ផលនេសាទកែច្នៃ ក្នុងខែវិច្ឆិកា អនុវត្តបានចំនួន៥០០តោន សរុបរយៈពេល១១ខែបានចំនួន៤.៧០០តោន ស្មើ៩៤% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.៣០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសជលផលមានចំនួន២៩៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន២៧៥ករណី និងបទល្មើសសមុទ្រចំនួន១៨ករណី

- បានផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន១០៨វគ្គ ដោយមានអ្នកចូលរួមចំនួន៩.៤១៦នាក់ ក្នុងនោះស្ត្រីចំនួន៣.៣២៥នាក់

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង១២៥.២០៧ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន២.២៨៤មាត់ បង្គោល/ចម្រឹងចំនួន៥៩.០០៤ដើម ឧបករណ៍ឆក់ត្រីចំនួន២៩គ្រឿង របាំងព្រួលប្រវែង៤៩៧ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្ដុរ/កោះរៀនជ្រូក)ចំនួន១២០គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៩.៤៩៩គ.ក្រ

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់/

បទល្មើសនេសាទតាមគ្រប់រូបភាព រួមទាំងការទប់ស្កាត់ការលួចចិញ្ចឹមត្រីរ៉ស់និងត្រីឆ្តោផងដែរ។

### ៥.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផល មកទល់ពេលនេះសរុបបានចំនួន៣.៤១១.៦៤៦.៩៧៥រៀល ស្មើ៩៥,៩៩% នៃផែនការ៣.៥៥៤.២៨១.២៥០រៀល (សម្រាប់រយៈពេល១១ខែដើមឆ្នាំ) ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៤៣០.៧១៩.៩៩៣រៀល។ ដោយឡែក ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ អនុវត្តបានចំនួន៣២៦.៩៨៦.០០០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ជ្រើសរើសទីតាំងនិងវាយតម្លៃការងារពិសោធន៍ស្រាវជ្រាវនៅខេត្តកំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង កំពត និងខេត្តព្រះវិហារ

- ចុះប្រមូលពូជដំណាំប្រពៃណី នៅខេត្តព្រះវិហារ ប្រមូលសំណាកជំងឺនិងសត្វល្អិតលើដំណាំសណ្តែកសៀង នៅខេត្តកំពង់ចាម ប្រមូលសំណាកទឹកនៅខេត្តតាកែវ

- ចុះប្រមូលព័ត៌មានពីកសិករស្តីពីការប្រើប្រាស់ម៉ាស៊ីនដាំគ្រាប់ស្ងួត នៅខេត្តតាកែវ។

## ៧ ផ្នែករដ្ឋបាល

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបណ្ណាញរក្សាទុកឯកសារ ការប្រើប្រាស់ប្រព័ន្ធអ៊ីម៉ែលនិងអ៊ិនធឺណែត ការចរាចរណ៍ឯកសារ និងការគ្រប់គ្រងឯកសាររដ្ឋបាលជូនមន្ត្រីរាជការក្រោមឱវាទក្រសួង

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣២២ច្បាប់ (សរុបរយៈពេល១១ខែចំនួន៤.៦៨០ច្បាប់) ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣២៨ច្បាប់ (សរុបរយៈពេល១១ខែចំនួន៣.៧២៤ច្បាប់) និងទទួលពីរាជធានីខេត្ត ក្នុងខែចំនួន៧៦ច្បាប់ (សរុបរយៈពេល១១ខែចំនួន១.២៨៦ច្បាប់) និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៨៩០ច្បាប់ (សរុបរយៈពេល១១ខែចំនួន៨.០៥០ច្បាប់) ចេញប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៣៧ច្បាប់ (សរុបរយៈពេល១១ខែចំនួន៥៩៤ច្បាប់) ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន១៨ច្បាប់ (សរុបរយៈពេល១១ខែចំនួន២៩៣ច្បាប់) និងផ្តល់ទិដ្ឋាការបេសកកម្មមន្ត្រីមន្ទីរកសិកម្មរាជធានី ខេត្តចំនួន៣៥ច្បាប់ សរុបមនុស្ស៥៩នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦៤០នាក់ នារីចំនួន១.៣៥១នាក់ ស្មើនឹង២០% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.០៥២នាក់ ក្នុងនោះនារីចំនួន៧៧៩នាក់ ស្មើនឹង១៩%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៨៧នាក់ ក្នុងនោះនារីចំនួន៥៧២នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០១នាក់ ក្នុងនោះសុំលាឈប់ពីការងារចំនួន០១នាក់

- ចេញច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន០១នាក់

- ប្រកាសផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៦នាក់

- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៥នាក់ និងក្នុងប្រទេសចំនួន០៩នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៥៧រូប នៅប្រទេសចំនួន៩

- អន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនចំនួន០៤ច្បាប់ សុំប័ណ្ណសម្គាល់និងស្លាកលេខរថយន្តONG ជូនអង្គការWelt Hungerhilfr, Wildlife Alliance ចំនួន២គ្រឿង សុំបន្ត

អនុស្សរណៈនៃការយោគយល់គ្នារវាងអង្គការAVEF ពន្យារទិដ្ឋាការស្នាក់នៅជូនទីប្រឹក្សាកូរ៉េចំនួន១រូប ផ្តល់យោបល់លើគម្រោង Early Harvest Projects និងលើកគម្រោងតាមផ្នែកសំខាន់ៗដើម្បីស្នើសុំទៅដៃគូពាក់ព័ន្ធ

- អន្តរាគមន៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីនាំចូលឧបករណ៍ត្រួតពិនិត្យនិងចត្តាឡីស័កពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដោយអនុវត្តគោលការណ៍ពន្ធជាបន្ទុករបស់រដ្ឋ

- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយគ្រប់ដៃគូ ទាំងអង្គការជាតិ-អន្តរជាតិ និងបណ្តាប្រទេសផ្តល់ជំនួយពាក់ព័ន្ធទាំងអស់ក្នុងវិស័យកសិកម្ម។

## ១០ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបចំនួន១.២២៣នាក់ (ស្រី៣៩៦នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាចំនួន១.០១៥នាក់(ស្រី៣៤៦នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន២០៨នាក់(ស្រី៤៦នាក់)។

និស្សិតសរុបមានការប្រែប្រួលថយចុះបន្តិចដោយសារនិស្សិតបានបញ្ចប់ការសិក្សាមានចំនួនច្រើនជាងនិស្សិតចូលថ្មី។ សាលាជាតិកសិកម្មព្រែកលៀបបានទទួលនិស្សិតថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាននិងបរិស្ថាន(ថ្នាក់បរិញ្ញាបត្ររងអាហារូបករណ៍)ឲ្យចូលរៀនសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ ជួសជុលអគារសិក្សាដេប៉ាតឺម៉ង់វិទ្យាសាស្ត្រជលផលនិងវិស្វកម្មកសិកម្មរួចរាល់ តភ្ជាប់ប្រព័ន្ធInternet ចូលគ្រប់ដេប៉ាតឺម៉ង់និងការិយាល័យដើម្បីនិស្សិតសិក្សាស្រាវជ្រាវ ចុះពិនិត្យនិងតាមដានការងារនៅស្ថានីយ៍ពិសោធន៍នៅស្រុកក្រាំកក់ ខេត្តតាកែវ។ អញ្ជើញអាជ្ញាធរដែនដីនិងប្រជាជននៅស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលមានការពាក់ព័ន្ធនឹងដីរបស់សាលាឲ្យចូលរួមប្រជុំ ដើម្បីឲ្យគាត់យល់ពីមូលហេតុដែលសាលាចុះបោះបង្គោលព្រំដី។ សហការជាមួយក្រុមហ៊ុនចិន Forword បង្រៀននិស្សិតនិងមន្ត្រីលើជំនាញកសិកម្ម និងបញ្ជូនមន្ត្រី២នាក់ទៅទស្សនកិច្ចសិក្សានៅចិន។ បន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន (Japonica seeds) ដឹកនាំនិស្សិតពិសោធន៍ដាំបន្លែក្នុងបរិវេណសាលា ចុះជួយសហគមន៍ជំរុញការដាំកូនឈើនៅឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងសហការជាមួយ Winnork International រៀបចំសិក្ខាសាលាដែលមាននិស្សិតចូលរួម១០០នាក់។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥ សរុបមានចំនួន១.២១៨នាក់(ស្រី៤៥៨នាក់) រួមមានៈ

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្រី៣៩១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់ (ស្រី២៩១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្រី៦៦នាក់) និងថ្នាក់បរិញ្ញារងចំនួន១១នាក់ (ស្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

បញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ និងនិស្សិតថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មឆ្នាំទី២ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្តាអង្គការនានា។ បន្តរៀបចំដំណើរការពិសោធន៍ដំណាំស្រូវរបស់គម្រោង HEQCIP/KCNSA/SGA45 នៅខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ ពិសោធន៍លើដំណាំខាត់ណាក្តោប ប្រសិទ្ធភាពជីអាសូត ផូស្វ័រ ប៉ូតាស្យូមទៅលើការលូតលាស់ដំណាំម្ទេសដៃនាង។ តាមដានការលូតលាស់ធំធាត់ជ្រូកបេក្នុងការចិញ្ចឹមតាមរយៈការផ្តល់ចំណីឧស្សាហកម្ម និងធ្វើការបង្កាត់ពូជកង្កែបនិងត្រីទីឡាព្យាក្រហម នៅសាលាជាតិកសិកម្មកំពង់ចាម។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើ

កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យចាប់ផ្តើមបវេសនកាលឆ្នាំសិក្សាថ្មីឆ្នាំ២០១៥-២០១៦ ហើយទទួលសិស្សថ្នាក់ទី១២ ទើបប្រឡងសញ្ញាបត្រទុតិយភូមិរួចថ្មីៗចំនួន១៥០នាក់មកធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីការសិក្សានៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលរៀបចំដោយ CJCC។ ប្រារព្ធពិធីសំណេះសំណាលជូនដំណើរដល់និស្សិតឆ្នាំទី៣ចំនួន១០២នាក់ ដែលត្រូវចេញទៅធ្វើកម្មសិក្សារយៈពេល១១ខែ នៅប្រទេសអ៊ីស្រាអែល។ សហការជាមួយសាកលវិទ្យាល័យ រដ្ឋមីស៊ីហ្គែន នៃសហរដ្ឋអាមេរិក ក្នុងការបើកវគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃគម្រោងកម្មវិធីជូនដល់មន្ត្រីរាជការនិងបុគ្គលិកអង្គភាពពាក់ព័ន្ធ និងសហការជាមួយស្ថានទូតអង់គ្លេស ដើម្បីផ្សព្វផ្សាយអាហារូបករណ៍ទៅសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ និងបណ្ឌិតនៅប្រទេសអង់គ្លេស ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ សាកលវិទ្យាល័យបានចុះហត្ថលេខាលើអនុស្សរណៈអំពីកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Shinji ប្រទេសជប៉ុន និងប្រជុំជាមួយគណៈប្រតិភូចលនាភូមិថ្មីរបស់កូរ៉េ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តកម្មវិធីចលនាភូមិថ្មីនៅក្នុងប្រទេសកម្ពុជា។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

១០.៤ សកម្មភាពផ្សេងៗ

ក. បានចូលរួមសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងដៃគូពាក់ព័ន្ធក្នុងសកម្មភាពយេនឌ័រនិងកុមារក៏ដូចជាការបញ្ជ្រាបកម្មវិធីនេះទៅក្នុងគម្រោងផ្សេងៗតាមផ្នែកសំខាន់ៗក្នុងវិស័យកសិកម្ម។ រៀបចំពិធីប្រកាសផ្សព្វផ្សាយនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០។

ខ. បន្តការចុះធ្វើអធិការកិច្ច ក៏ដូចជាកិច្ចការសវនកម្មផ្ទៃក្នុងបានប្រព្រឹត្តទៅតាមផែនការឆ្នាំ២០១៥ ដែលបានគ្រោងទុក។

គ. ការចុះត្រួតពិនិត្យ ការងារផ្សព្វផ្សាយអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តច្បាប់ក្នុងការគ្រប់គ្រងសម្ភារកសិកម្ម ក៏បានដំណើរការទៅតាមផែនការដែលបានដាក់ចុះក្នុងឆ្នាំ២០១៥ ជាអាទិ៍: (១)-រៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារនីតិកម្មកសិកម្មប្រចាំឆមាសទី១ ឆ្នាំ២០១៥ ដែលមានអ្នកចូលរួមសរុបចំនួន៧៧នាក់។ (២)-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីនីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម ដែលមានអ្នកចូលរួមចំនួន១៤០នាក់។ (៣)-បើកវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំរបស់អាស៊ាន ស្តីពីបទដ្ឋានគតិយុត្តក្នុងការប្រើប្រាស់ និងការធ្វើពាណិជ្ជកម្មភ្នាក់ងារជីវសាស្ត្រ(BCA) ដោយសហការជាមួយអង្គការ GIZ ដែលមានអ្នកចូលរួមចំនួន១៨នាក់។ (៤)-បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយនូវច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម នៅខេត្តត្បូងឃ្មុំ មណ្ឌលគិរី ព្រះសីហនុ កំពត កំពង់ស្ពឺ ព្រះវិហារ សៀមរាប កំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង រតនគិរី និងខេត្តស្ទឹងត្រែង ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៦១៦នាក់។ (៥)-សហការជាមួយមន្ទីរកសិកម្មខេត្តរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើជាគ្រូឧទ្ទេសនាមដល់អាជីវករលក់ដុំ លក់រាយសម្ភារកសិកម្ម នៅខេត្តកំពង់ចាម មណ្ឌលគិរី កណ្តាល បន្ទាយមានជ័យ រតនគិរី ស្វាយរៀង ដែលមានសិក្ខាកាមចូលរួមសរុបចំនួន២៨៥នាក់។ (៦)-បែងចែកឯកសារច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មចំនួន២.៦៨០ក្បាល ឯកសារបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មចំនួន៦១០ក្បាល ប្រកាសលេខ០៩៩ ប្រក.កសក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្មចំនួន១០៥ច្បាប់ និងឯកសារសម្រាប់មន្ត្រីអធិការកិច្ចស្តីពីថ្នាំកសិកម្មហាមឃាត់និងថ្នាំកសិកម្មអនុញ្ញាតឱ្យប្រើប្រាស់ស្ថិតក្នុងលក្ខខណ្ឌចំនួន១.៥៩៥ក្បាល។

III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

នៅក្នុងឆ្នាំនេះ ស្ថានភាពនៃការងារបង្កបង្កើនផលមានការប្រែប្រួល អាស្រ័យដោយសារអាកាសធាតុមិនអំណោយ

ផល ទឹកភ្លៀងធ្លាក់យឺតជាងឆ្នាំកន្លងមក និងគ្រោះរាំងស្ងួតបានអូសបន្លាយពេលយូរនៅដើមរដូវវស្សា។ ជាមួយគ្នានេះដែរ ទឹកទន្លេឆ្នាំនេះមានកម្រិតទាបមិនអាចហូរចូលព្រែកបាន ក៏ជាកត្តាមួយជះឥទ្ធិពលដល់ការងារបង្កបង្កើនផលទាំងរដូវវស្សា និងរដូវប្រាំងផងដែរ។ តែទោះជាយ៉ាងណាការងារបង្កបង្កើនផលស្រូវរដូវវស្សា ក៏ដូចជារដូវប្រាំងមិនមានទទួលរងនូវជំងឺ ឬសត្វចង្រៃបំផ្លាញផលដំណាំឡើយ។ ម្យ៉ាងទៀត តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក៏ដូចជាការថែទាំដំណាំតាមដំណាក់កាលលូតលាស់ ការប្រើប្រាស់ពូជល្អពេញនិយមនិងមានទិន្នផលខ្ពស់ ស្របតាមតម្រូវការនៃទីផ្សារ គួបផ្សំនឹងការកាត់បន្ថយការប្រើប្រាស់ជីកសិកម្ម និងកត្តាផលិតកម្មផ្សេងៗទៀតបានធ្វើឲ្យការងារបង្កបង្កើនផលទទួលបានលទ្ធផលជាវិជ្ជមាន។

តាមរយៈការបូកសរុបបឋម លទ្ធផលប៉ាន់ស្មានជំហានដំបូងលើការងារបង្កបង្កើនផលស្រូវឆ្នាំ២០១៥-២០១៦ នឹងអាចសម្រេចបានលើផ្ទៃដីបង្កបង្កើនផលចំនួន៣.០២៧.១២៤ហិកតា (រដូវវស្សា២.៥៦១.៩៥៧ហិកតា និងរដូវប្រាំង ៤៦៥.១៦៧ហិកតា) តិចជាងឆ្នាំមុនចំនួន២៨.៣៨៣ហិកតា(ឆ្នាំមុនអនុវត្តបានចំនួន៣.០៥៥.៥០៧ហិកតា)។ ផ្ទៃដីប្រមូលផលសរុបអាចទទួលបានចំនួន២.៩៩៦.២៥៩ហិកតា(រដូវវស្សា២.៥៣៦.១៩៧ហិកតា និងរដូវប្រាំង៤៦០.០៦២ ហិកតា) តិចជាងឆ្នាំមុនចំនួន៣២.៥៧៧ហិកតា (ឆ្នាំមុនអនុវត្តបានជាង៣.០២៨លានហិកតា)។ បរិមាណផលប៉ាន់ស្មានសរុប៩.២២៧.០១២តោន (ឆ្នាំមុន៩,៣២លានតោន) និងទិន្នផលមធ្យមទូទាំងប្រទេសចំនួន៣,០៨០តោន/ហិកតា (ឆ្នាំមុន៣.០៧៩តោន/ហិកតា)។ ដូចនេះ បើគិតពីតុល្យភាពស្បៀងរវាងសេចក្តីត្រូវការ និងបរិមាណផលស្រូវទទួលបាន ឃើញថា អាចនៅសល់បរិមាណស្បៀងគិតជាស្រូវជាង៤,៥លានតោន (ឆ្នាំមុនសម្រេចបាន៤,៧លានតោន) និងគិតជាអង្ករប្រមាណជាង២,៩១លានតោន (ឆ្នាំមុនជាង៣,០១លានតោន)សម្រាប់នាំចេញ។

ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល គឺស្ថិតនៅតែជាប្រធានបទអាទិភាព ដែលអង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយរហូតដល់មន្ត្រីជំនាញមួយចំនួនទទួលរងនូវការគំរាមកំហែង និងគ្រោះថ្នាក់ដល់អាយុជីវិតក៏មាន។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៥នេះ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវវស្សានេះឱ្យបានសម្រេចតាមផែនការ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីស្តារការដាំដុះឡើងវិញឱ្យបានទាន់ពេលវេលានៅតំបន់ដែលទទួលរងការខូចខាតដោយគ្រោះរាំងស្ងួត ព្រមទាំងត្រៀមបម្រុងគ្រាប់ពូជស្រូវសម្រាប់ផ្តល់ជូនកសិករក្រីក្រដែលពុំមានលទ្ធភាពទិញគ្រាប់ពូជ ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឱ្យធ្វើការដាំដុះស្រូវស្រាលឬស្រូវកណ្តាល ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់

អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន ព្រមទាំងកសិករ ម្ចាស់ម៉ាស៊ីនកិនស្រូវ និងអ្នកទិញ-លក់ស្រូវអង្ករមានវិធានការជាបន្ទាន់ដោយប្រើប្រាស់កម្លាំងសរុប ដើម្បីជំរុញការថែទាំស្រូវវស្សា ព្រមទាំងទប់ស្កាត់ការបាត់បង់ទាំងបរិមាណនិងគុណភាពស្រូវអង្ករនៅពេលប្រមូលផល សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឱ្យទទួលបានជោគជ័យនិងជំរុញការដាំដុះស្រូវប្រាំងឱ្យទទួលបានលទ្ធផលល្អក្នុងន័យធានាបាននូវសន្តិសុខស្បៀងនិង ការកាត់បន្ថយភាពក្រីក្រ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងកូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខ័ណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

**២ ផ្នែកផលិតកម្មនិងបសុព្យាបាល :**

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺផ្តួកត្រចៀកខៀវ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វនិងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺផ្តួកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្តពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែករុក្ខាប្រមាញ់ :**

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្ដារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ

- ពង្រឹងការអនុវត្តច្បាប់ស្ដីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

៤ វិស័យជលផល :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយុទ្ធការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទជាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) វារីវប្បកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

៥ វិស័យពាក់ព័ន្ធផ្សេងៗ :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្ដាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវរបស់ផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹម

នឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្ដែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្ដុះបណ្ដាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- រៀបចំក្រុមការងារដើម្បីទទួលខុសត្រូវក្នុងការធ្វើវិសោធនកម្មច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្ដង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ធ្វើពាណិជ្ជកម្មក្នុងការត្រៀមលក្ខណៈសមាហរណកម្មចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងនាពេលអនាគត៕

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន